# អនុក្រឹត្យលេខ ៣០ អនក្រ.បក
## ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅ
## របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០០/០០៧ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩

## សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ កំណត់ការរៀបចំនិងការប្រព្រឹត្តិទៅរបស់អាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ហៅកាត់ អ.ជ.ប.ជ.អ ក្នុងគោលដៅបង្ការទប់ស្កាត់ការចម្លងមេរោគអេដស៍ និងបន្ថយល្បឿនការរីករាលដាលនៃជំងឺអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២ .-**

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានរាជរដ្ឋាភិបាលប្រគល់តួនាទីជូនធ្វើជាសេនាធិការក្នុងកិច្ចទទួលខុសត្រូវរួម លើវិធានការការពារនិងព្យាបាលព្រមទាំងទប់ស្កាត់ការរីករាលដាល នៃជំងឺអេដស៍ ហើយមានភារកិច្ចដូចតទៅ :

១-លើកគោលនយោបាយជាតិប្រយុទ្ធនឹងជំងឺអេដស៍

២-រៀបចំយុទ្ធសាស្ត្រសំរាប់អនុវត្តគោលនយោបាយជាតិ

៣-សំរបសំរួល ណែនាំ និងបង្កលក្ខណៈអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ នៅតាមបណ្តាស្ថាប័នពាក់ព័ន្ធនានា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនអោយមាននិរន្តរភាព

៤-ស្វែងរកជំនួយពីគ្រប់មូលដ្ឋានជាតិនិងអន្តរជាតិ ដើម្បីគាំទ្រការអនុវត្តន៍ផែនការជាតិប្រយុទ្ធនឹងជំងឺអេដស៍

៥-លើកយោបល់ជូនរាជរដ្ឋាភិបាល អំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងសភាពការនៃជំងឺអេដស៍

៦-ផ្លាស់ប្តូរបច្ចេកទេស និងបទពិសោធន៍ជាមួយប្រទេសទាំងឡាយណាដែលមានបញ្ហាអេដស៍

៧-ទ្រទ្រង់ សំរបសំរួល និងសហការធ្វើការស្រាវជ្រាវអេពីដេមីសាស្ត្រ និងស្រាវជ្រាវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនិងសង្គម នៃជំងឺអេដស៍

៨-ផ្តល់យោបល់ ណែនាំស្តីពីវិធានការដែលមានចែងក្នុងមាត្រា២ ខាងលើនៃអនុក្រឹត្យនេះដល់មន្ទីរពិសោធន៍ មន្ទីរពេទ្យនិងកន្លែងថែទាំ ព្យាបាល អ្នកផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍

៩-ពិនិត្យអនុម័តលើគំរោងកម្មវិធីអប់រំ ដែលត្រូវធ្វើការផ្សព្វផ្សាយនៅតាមក្រសួង ស្ថាប័នសាលារៀន តាមវិទ្យុ ទូរទស្សន៍ និងលើកម្មវិធីអប់រំដោយផ្ទាល់

១០-ទទួលខុសត្រូវរៀបចំច្បាប់ និងចេញលិខិតបទដ្ឋានទាំងឡាយស្តីពីការត្រួតពិនិត្យនិងការអនុវត្តន៍បទប្បញ្ញត្តិផ្សេងៗដែលទាក់ទងនឹងជំងឺអេដស៍ ដោយសង្កត់ធ្ងន់លើវិស័យសិទ្ធិ មនុស្ស ។

មាត្រា ៣ ._

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១-ប្រធាន | ១ រូប | |
| ២-អនុប្រធានប្រចាំការ | ១ រូប | |
| ៣-អនុប្រធានជំនួយការ | ១ រូប | |
| ៤-អគ្គលេខាធិការ | ១ រូប | |
| ៥-ទីប្រឹក្សា | ៣ រូប | |
| ៦-រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| ៧-រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា | ១ រូប | ជាសមាជិក |
| ៨-រដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា | ១ រូប | ជាសមាជិក |
| ៩-រដ្ឋលេខាធិការក្រសួងការពារជាតិ | ១ រូប | ជាសមាជិក |
| ១០-រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១ រូប | ជាសមាជិក |
| ១១-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១ រូប | ជាសមាជិក |
| ១២-រដ្ឋលេខាធិការក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន | ១ រូប | ជាសមាជិក |
| ១៣-រដ្ឋលេខាធិការក្រសួងពត៌មាន | ១ រូប | ជាសមាជិក |
| ១៤-រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១ រូប | ជាសមាជិក |

១៥-រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១ រូប ជាសមាជិក
១៦-រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១ រូប ជាសមាជិក
១៧-រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១ រូប ជាសមាជិក
១៨-រដ្ឋលេខាធិការក្រសួងផែនការ ១ រូប ជាសមាជិក
១៩-អភិបាលរងរាជធានីភ្នំពេញ ១ រូប ជាសមាជិក
២០-អភិបាលរងខេត្ត ក្រុងនិមួយៗ ១ រូប ជាសមាជិក

មាត្រា ៤ ._

រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាប្រធាននៃ អ.ជ.ប.ជ.អ ដោយប្រស្ស៍យប្រវត្តិ ។

ប្រធានប្រគល់សិទ្ធិគ្រប់គ្រងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អោយអនុប្រធានប្រចាំការ ។

ប្រធានទទួលខុសត្រូវ លើការងារ អ.ជ.ប.ជ.អ

-ធ្វើជាអធិបតីភាពក្នុងអង្គប្រជុំ អ.ជ.ប.ជ.អ

-ដឹកនាំពិភាក្សា និងប្តូកសរុបមតិសំរេចរបស់អង្គប្រជុំ អ.ជ.ប.ជ.អ

-កោះប្រជុំសាមញ្ញ ឬក្នុងករណីចាំបាច់ប្រជុំវិសាមញ្ញនៃអង្គប្រជុំ អ.ជ.ប.ជ.អ

មាត្រា ៥ ._

អនុប្រធានប្រចាំការ អ.ប.ជ.អ មានឋានៈស្មើនឹងរដ្ឋមន្ត្រី មានតួនាទីនិងភារកិច្ចដូចតទៅ :

-ទទួលខុសត្រូវជាទូទៅលើការងារ អ.ជ.ប.ជ.អ

-ទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ អ.ជ.ប.ជ.អ

-ធ្វើជាអធិបតីក្នុងអង្គប្រជុំ អ.ជ.ប.ជ.អ ក្នុងករណីអវត្តមានរបស់ប្រធាន និងចុះហត្ថលេខាលើកំណត់ហេតុនិងសេចក្តីជូនដំណឹង នៃអង្គប្រជុំរបស់ អ.ជ.ប.ជ.អ

-ទទួលបន្ទុកការងារសំរបសំរួលអន្តរក្រសួង រវាង អ.ជ.ប.ជ.អ ជាមួយក្រសួងស្ថាប័ននានា នៃរាជរដ្ឋាភិបាល

-ទទួលបន្ទុកទំនាក់ទំនង និងសំរបសំរួលធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធក្នុងវិស័យអេដស៍ ។

មាត្រា ៦ ._

ក្នុងការបំពេញភារកិច្ចទាំងឡាយនេះ អនុប្រធានប្រចាំការ មានអនុប្រធានជំនួយការមួយរូបដែលមានឋានៈស្មើរដ្ឋលេខាធិការ និងទីប្រឹក្សាមួយចំនួន ។

មាត្រា ៧ ._

អ.ជ.ប.ជ.អ បើកសម័យប្រជុំពេញអង្គរបស់ខ្លួនយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ក្រោមអធិបតីភាពរបស់ប្រធាន ឬអនុប្រធានប្រចាំការ ក្នុងករណីអវត្តមានរបស់ប្រធាន ។ តំណាងម្ចាស់ជំនួយអាចចូលរួមក្នុងកិច្ចប្រជុំ អ.ជ.ប.ជ.អ ជាអ្នកសង្កេតការណ៍ដែលមិនត្រូវមានចំនួនលើសពីបួននាក់ឡើយ ។

មាត្រា ៨ .-

ដើម្បីបំពេញបាននូវបេសកកម្មរបស់ខ្លួន អ.ជ.ប.ជ.អ មានសិទ្ធិអំណាចចេញបទដ្ឋានផ្សេងៗក្នុងវិស័យប្រេងរុក្ខនិងជីវឧស្ម័ន ដែលមានលក្ខណៈជាទូទៅក្តី ជាបុគ្គលក្តី ដែលអាជ្ញាធរគ្រប់ជាន់ថ្នាក់ត្រូវយកទៅអនុវត្តឲ្យមានប្រសិទ្ធភាព ។

មាត្រា ៩ .-

អ.ជ.ប.ជ.អ មានសិទ្ធិប្រើប្រាស់ ត្រាផ្ទាល់របស់ខ្លួន ។

មាត្រា ១០ .-

រចនាសម្ព័ន្ធ អ.ជ.ប.ជ.អ មានដូចខាងក្រោម :

-ខុទ្ទកាល័យ អ.ជ.ប.ជ.អ

-អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

-ក្រុមប្រឹក្សាបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ។

## ជំពូកទី ៣
## ខុទ្ទកាល័យ អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាបច្ចេកទេស

មាត្រា ១១ .-

ខុទ្ទកាល័យ អ.ជ.ប.ជ.អ ទទួលបន្ទុកបេសកកម្ម និងភារកិច្ចទាំងឡាយដែលមានកំណត់តាមបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន ។

មាត្រា ១២ .-

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ចែកចេញជាផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសមួយចំនួន ព្រមទាំងមានក្រុមប្រឹក្សាបច្ចេកទេសមួយ ជាជំនួយការ ។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ត្រូវបានដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលអាចអមដោយអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់ ។

ការរៀបចំនិងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ត្រូវកំណត់ដោយប្រកាស របស់ អ.ជ.ប.ជ.អ ។

មាត្រា ១៣ .-

អគ្គលេខាធិការ អ.ជ.ប.ជ.អ មានតួនាទីនិងភារកិច្ចដូចតទៅ :

-ទទួលបន្ទុកចាត់ចែង គ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.ជ.អ

-រៀបចំកម្មវិធីការងារ អ.ជ.ប.ជ.អ និងរៀបចំរបៀបវារៈ និងសំណុំឯកសារផ្សេងៗសំរាប់អង្គប្រជុំ អ.ជ.ប.ជ.អ និងអង្គប្រជុំរបស់ក្រុមប្រឹក្សាបច្ចេកទេស

-រៀបចំកំណត់ហេតុ សេចក្តីជូនដំណឹងការប្រជុំរបស់ អ.ជ.ប.ជ.អ និងការប្រជុំរបស់ក្រុមប្រឹក្សាបច្ចេកទេស ដើម្បីដាក់ជូនប្រធាន អ.ជ.ប.ជ.អ ចុះហត្ថលេខា

-រៀបចំរបាយការណ៍ អ.ជ.ប.ជ.អ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ

-រៀបចំប្រកាសព័ត៌មានរបស់ អ.ជ.ប.ជ.អ

-ចូលរួមក្នុងអង្គប្រជុំ អ.ជ.ប.ជ.អ និងធ្វើជាអធិបតីក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាបច្ចេកទេស

-បំពេញការងារផ្សេងៗទៀតដែលប្រធាន និងអនុប្រធាន អ.ជ.ប.ជ.អ ប្រគល់អោយ ។

**មាត្រា ១៤ ._**

អគ្គលេខាធិការរងនីមួយៗបំពេញកិច្ចការតាមភារកិច្ច ដែលអគ្គលេខាធិការប្រគល់អោយ ។

**មាត្រា ១៥ ._**

ក្រុមប្រឹក្សាបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ មានសមាជិកជាមន្ត្រីដែលមានបទពិសោធន៍ក្នុងបញ្ហាអេដស៍ មកពីក្រសួងពាក់ព័ន្ធទាំង ១៣ ។

**មាត្រា ១៦ ._**

ក្រុមប្រឹក្សាបច្ចេកទេសនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ ត្រូវប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ ក្រោមអធិបតីភាពរបស់អគ្គលេខាធិការនៃ អ.ជ.ប.ជ.អ ដើម្បី :

-រៀបចំយុទ្ធសាស្ត្រសំរាប់អនុវត្តគោលនយោបាយជាតិ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ជំងឺអេដស៍

-រៀបចំផែនការអភិវឌ្ឍន៍តាមបច្ចេកទេស ក្នុងវិស័យអេដស៍

-ណែនាំអនុវត្តយុទ្ធសាស្ត្រដើម្បីឆ្លើយតបដោយប្រសិទ្ធភាព ទៅនឹងតំរូវការនៃស្ថានភាពជំងឺអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤

## អំពីការអនុវត្តន៍គោលនយោបាយ អ.ជ.ប.ជ.អ

**មាត្រា ១៧ ._**

សមាជិក អ.ជ.ប.ជ.អ ដែលតំណាងអោយក្រសួងទាំង ១៣ រាជធានីភ្នំពេញនិងខេត្ត ក្រុង នីមួយៗ ត្រូវទទួលខុសត្រូវចំពោះមុខ អ.ជ.ប.ជ.អ ក្នុងការអនុវត្តន៍គោលនយោបាយតាមយុទ្ធសាស្ត្រ ដែលបានកំណត់ដោយ អ.ជ.ប.ជ.អ ។

**មាត្រា ១៨ ._**

ក្នុងការអនុវត្តន៍ផែនការ ឆ្លើយតបនឹងការរីករាលដាល នៃមេរោគអេដស៍ ជំងឺអេដស៍ អ.ជ.ប.ជ.អ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានីភ្នំពេញ ខេត្ត-ក្រុង និង ខណ្ឌ-ស្រុក ដែលមានស្រាប់ ។

## ជំពូកទី ៥
## ប្រភពធនធាននិងការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៩ ._**

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលជាស្ថាប័នជាតិនៃព្រះរាជាណាចក្រកម្ពុជា មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងកញ្ចប់ថវិកានៃក្រសួងសុខាភិបាល សំរាប់វិស័យអេដស៍និងដោយជំនួយពីក្នុង និងក្រៅប្រទេស ។

**មាត្រា ២០ ._**

រាល់បុគ្គលិករបស់ អ.ជ.ប.ជ.អ គឺជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។

**មាត្រា ២១ ._**

អគ្គលេខាធិការដ្ឋានត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុ ដោយមានការឯកភាពពីនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាលជូន អ.ជ.ប.ជ.អ រៀងរាល់ត្រីមាស ។ ការត្រួតពិនិត្យគណនេយ្យ ត្រូវប្រគល់ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលត្រូវបានតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២២ ._**

អ.ជ.ប.ជ.អ មានភារកិច្ចប្រើប្រាស់ថវិកាដែលបានទទួល អោយមានប្រសិទ្ធភាព និង និរន្តរភាព ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ២៣ ._**

រាល់អនុក្រឹត្យ និងសេចក្តីសំរេចពីមុន ដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៤ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត ក្រុង និងមន្ត្រីរាជការ ដែលមានចែងក្នុងមាត្រា ៣ ត្រូវអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល

និងជាប្រធាន អជបជអ

**ហុង ស៊ុនហួត**

***